**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ឈ្ម.ក/លេខ ០៥.០៩៦/០៩ គ.ជ.ប.អគ្គ.៣៥**

រាជធានីភ្នំពេញ ថ្ងៃទី 16 ខែឧសភា ឆ្នាំ២០០៩

# បេក្ខជនឈរឈ្មោះបោះឆ្នោតចំនួន ៤១នាក់ ត្រូវបានលុបឈ្មោះ ចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៩ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចលុបឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោត ចំនួន ៤១នាក់ ចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឆ្នាំ២០០៩ ដោយសារបេក្ខជនទាំងនោះមានអាយុមិនគ្រប់ ២៥ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត ។

ឈ្មោះបេក្ខជន ចំនួន ៣នាក់ គឺ ២នាក់ ឈរឈ្មោះនៅមណ្ឌលបោះឆ្នោត ខេត្តកំពង់ចាម និង ១នាក់ ទៀត ឈរឈ្មោះនៅមណ្ឌលបោះឆ្នោត ខេត្តប៉ៃលិន ត្រូវបានលុបចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្ស សម រង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិច ។ ចំណែកឈ្មោះបេក្ខជន ចំនួន ៣៨នាក់ទៀត ត្រូវបានលុបចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់ គណបក្សនយោបាយ ចំនួន ៤ គឺ គណបក្សប្រជាជនកម្ពុជា គណបក្ស សម រង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្ស នរោត្តម រណឫទ្ធិ នៅមណ្ឌលបោះឆ្នោតក្រុង ស្រុក ចំនួន ២៤ ៖

- ស្រុកស្វាយចេក ក្នុងខេត្តបន្ទាយមានជ័យ
- ស្រុកថ្មគោល និងស្រុកបាណន់ ក្នុងខេត្តបាត់ដំបង
- ក្រុងកំពង់ចាម ស្រុកជើងព្រៃ ស្រុកក្រូចឆ្មារ ស្រុកស្ទឹងត្រង់ ស្រុកបាធាយ ស្រុកតំបែរ និងស្រុកកំពង់សៀម ក្នុងខេត្តកំពង់ចាម
- ក្រុងកំពង់ឆ្នាំង ក្នុងខេត្តកំពង់ឆ្នាំង
- ស្រុកឈូក ស្រុកកំពង់ត្រាច ក្រុងកំពត ស្រុកដងទង់ ស្រុកបន្ទាយមាស និងស្រុកជុំគិរី ក្នុងខេត្តកំពត
- ស្រុកព្រះស្ដេច ស្រុកពារាំង និងស្រុកស្វាយអន្ទរ ក្នុងខេត្តព្រៃវែង
- ក្រុងព្រះសីហនុ ក្នុងខេត្តព្រះសីហនុ
- ស្រុករមាសហែក ក្នុងខេត្តស្វាយរៀង
- ក្រុងប៉ៃលិន ក្នុងខេត្តប៉ៃលិន
- ស្រុកអន្លង់វែង ក្នុងខេត្តឧត្តរមានជ័យ ។

ចំពោះព័ត៌មានលំអិតទាក់ទងទៅនឹងឈ្មោះបេក្ខជនទាំង ៤១នាក់ នេះ មាននៅក្នុងគេហទំព័រ គ.ជ.ប (Website: www.necelect.org.kh) ។/